គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

# វេទិកាវៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៤៣

## ក្រោមប្រធានបទ "អត្ថប្រយោជន៍និងវិធានការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក"

ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០២៦

ម៉ោង ៨:០០ ដល់ ៥:០០ ល្ងាច

តាមរយៈការចូលរួមផ្ទាល់នៅភោជនីយដ្ឋានទន្លេបាសាក់២ និងតាមប្រព័ន្ធអនឡាញ **Zoom Meeting**

### ១. សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាពដ៏ធំ និងមានវ័យចំណាស់ជាងគេមួយនៅក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០២៦ អង្គការ គ.ស.ក មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសចំនួន១៩១ស្ថាប័ន។ បច្ចុប្បន្ននេះ អង្គការ គ.ស.ក បានកំពុងអនុវត្តកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ចដំណាក់កាលទី៥ ពីឆ្នាំ២០២៤ ដល់ ២០២៨។ កម្មវិធីនេះ មានគោលបំណងសំខាន់គឺពង្រឹងអង្គការសង្គមស៊ីវិលតាមរយៈការធ្វើអោយប្រសើរឡើងនូវបរិយាកាសអំណោយផល និងលំហាប្រជាធិបតេយ្យ។

ច្បាប់ស្តីពី **បេឡាជាតិរបបសន្តិសុខសង្គមជាតិ** (NSSF) មានតួនាទីយ៉ាងសំខាន់ក្នុងការការពារសុខុមាលភាពរបស់បុគ្គលិក តាមរយៈការធានាសិទ្ធិទទួលបានអត្ថប្រយោជន៍ដូចជា ការធានាគ្រោះថ្នាក់ការងារ ការថែទាំសុខភាព និងការការពារផ្នែកសង្គមផ្សេងៗ។ ការយល់ដឹងឱ្យបានច្បាស់អំពីអត្ថប្រយោជន៍ និងវិធានការអនុវត្តច្បាប់នេះ មិនត្រឹមតែជួយឲ្យអង្គការអនុវត្តតាមច្បាប់បានត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយបង្កើនទំនុកចិត្ត និងទំនាក់ទំនងល្អរវាងនិយោជក និងនិយោជិតផងដែរ។

ជាមួយគ្នានេះដែរ **ប្រព័ន្ធវាយតម្លៃសមិទ្ធផលការងាររបស់បុគ្គលិក** គឺជាឧបករណ៍សំខាន់សម្រាប់ជំរុញសមត្ថភាព និងសមិទ្ធផលអង្គការ។ ការកំណត់សូចនាករសមិទ្ធផលសំខាន់ (KPI) ការវាយតម្លៃដោយយុត្តិធម៌ និងការផ្តល់មតិយោបល់ស្ថាបនាគឺជាកត្តាជួយឲ្យបុគ្គលិកយល់អំពីការរំពឹងទុក កាត់បន្ថយគម្លាតសមិទ្ធផល និងលើកកម្ពស់ការកែលម្អបន្ត។ ការអនុវត្តប្រព័ន្ធនេះបានល្អ នឹងរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្ស ការទទួលខុសត្រូវ និងវប្បធម៌ការងារដែលផ្អែកលើសមិទ្ធផល។

ក្នុងបរិបទការងារបច្ចុប្បន្ន ដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ការពង្រឹងរបបសន្តិសុខសង្គមដ៏រឹងមាំ និងប្រព័ន្ធវាយតម្លៃសមិទ្ធផលការងារដែលមានប្រសិទ្ធភាព គឺជាកត្តាសំខាន់ក្នុងការអភិវឌ្ឍកម្លាំងពលកម្មឲ្យមានស្ថេរភាព ស្មារតីល្អ និងសមិទ្ធផលខ្ពស់។ ដោយយល់ឃើញពីសារៈសំខាន់នេះ វេទិកាវៀនសូត្រស្តីអំពី "អត្ថប្រយោជន៍និងវិធានការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងការវាយតម្លៃការបំពេញការងារ

របស់បុគ្គលិក" ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងសម្រាប់អ្នកជំនាញផ្នែកធនធានមនុស្ស អ្នកគ្រប់គ្រង និងថ្នាក់ដឹកនាំអង្គការ។

ដូច្នេះ អង្គការគ.ស.ក នឹងរៀបចំវេទិការៀនសូត្រស្តីពី "**អត្ថប្រយោជន៍និងវិធានការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក**" ដែលវេទិកានេះ នឹងប្រព្រឹត្តឡើងនាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ និងតាមរយៈអនឡាញហ្ស៊ូម។

## ២. គោលបំណងនៃវេទិការៀនសូត្រ

គោលបំណងនៃវេទិការៀនសូត្រ រយៈពេលមួយថ្ងៃនេះគឺ៖

1. ដើម្បីបង្កើនការយល់ដឹងដល់អ្នកចូលរួមអំពីរបបសន្តិសុខសង្គម និងការអនុវត្តជាក់ស្តែង។
2. ដើម្បីពង្រឹងការយល់ដឹងបន្ថែមអំពីវិធីសាស្ត្រនៃការវាយតម្លៃការបំពេញការងាររបស់បុគ្គលិករួមមានគោលបំណង វិធីសាស្ត្រ និងការអនុវត្តន៍។
3. ដើម្បីចែករំលែកបទពិសោធន៍ និងកសាងបណ្តាញទំនាក់ទំនងរវាងអ្នកចូលរួម។

## ៣. អ្នកចូលរួម និងការកំណត់តម្លៃនៃការចូលរួមក្នុងវេទិការៀនសូត្រ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស ដែលអញ្ជើញមកពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។

- **ការចូលរួមដោយផ្ទាល់**
  - **សម្រាប់អង្គការសមាជិករបស់ គ.ស.ក នឹងត្រូវបានផ្តល់ជូន ០២ កន្លែង សម្រាប់អង្គការសមាជិកនីមួយៗ បើមកលើសពីការកំណត់នឹងតម្រូវអោយបង់បដិភាគ២៥$/ម្នាក់។**
  - **អង្គការមិនមែនសមាជិក តម្រូវអោយបង់បដិភាគ ៥០$/ម្នាក់សម្រាប់ការចូលរួមដោយផ្ទាល់ (ក្នុងករណីមាននៅសល់កន្លែង)។**
- **ការចូលរួមតាមរយៈប្រព័ន្ធអនឡាញហ្ស៊ូម (Zoom)**
  - ផ្តល់ជូន ០២ កន្លែងសម្រាប់សមាជិករបស់អង្គការ គ.ស.ក។ បើមកលើសពីការកំណត់នឹងតម្រូវអោយបង់បដិភាគ១០$/ម្នាក់។
  - សម្រាប់អង្គការមិនមែនសមាជិកតម្រូវអោយបង់បដិភាគ២០$/ម្នាក់សម្រាប់ការចូលរួមតាមអនឡាញ។

**សម្គាល់៖** ចំនួនមានកំណត់ សូមចុះឈ្មោះជាមុនតាមរយៈតំណរចុះឈ្មោះដែលបានផ្តល់ជូនខាងក្រោម។
https://www.ccc-cambodia.org/kh/resources/event-calendar/2026-05-21/hr-learning-forum-13

## ៤. របៀបចុះឈ្មោះ

អ្នកចូលរួមទាំងអស់តម្រូវឲ្យចុះឈ្មោះជាមុន ដើម្បីកំណត់ពីការអញ្ជើញចូលរួមដោយផ្ទាល់ ឬដើម្បីអាចទទួលបានតំណរទៅកាន់វេទិការៀនសូត្រ (Zoom Link) ពីក្រុមការងារ អង្គការ គ.ស.ក សម្រាប់អ្នកចូលរួមតាមប្រព័ន្ធអនឡាញ។ តំណរ (Zoom Link) នឹងផ្ញើជូន អ្នកដែលបានចុះឈ្មោះ និងបំពេញតាមលក្ខខណ្ឌតែប៉ុណ្ណោះ (មួយថ្ងៃ មុនវេទិការៀនសូត្រចាប់ផ្តើម)។

## ៥. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០ -០៨:៣០ | ❖ ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គ.ស.ក |
| ០៨:៣០-០៨:៤០ | ❖ ការណែនាំពី បទបញ្ជាផ្ទៃក្នុងសម្រាប់វេទិការៀនសូត្រ<br>❖ គោរពភ្លេងជាតិ<br>❖ ប្រកាសគោលបំណងវេទិការៀនសូត្រ | **អ្នករៀបចំកម្មវិធី**<br>អង្គការ គ.ស.ក |
| ០៨:៤០-៩:០០ | ❖ កិច្ចស្វាគមន៍ និងបើកកម្មវិធីតំណាងអង្គការ គ.ស.ក | **លោក ច័ន្ទ ភក្តី**<br>នាយកប្រតិបត្តិនៃអង្គការ គ.ស.ក |
| ៩:០០ -១០:០០ | ❖ បទ**<u>បង្ហាញស្តីពី៖</u>** របបសន្តិសុខសង្គម អត្ថប្រយោជន៍ និងការអនុវត្តវិធាននានាតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម | **មន្ត្រីតំណាងពី បសស** |
| ១០:០០ -១០:១៥ | ❖ **ការថតរូបជុំគ្នា និងសម្រាកពិសារអាហារសម្រន់** | |
| ១០:១៥ -១១:០០ | ❖ **<u>បន្តបទបង្ហាញស្តីពី៖</u>** របបសន្តិសុខសង្គម អត្ថប្រយោជន៍ និងការអនុវត្តវិធាននានាតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម | **មន្ត្រីតំណាងពី បសស** |
| ១១:០០ -១២:០០ | ***(សំណួរនិងចម្លើយ)*** | |
| ១២:០០-១:៣០ | ❖ **ពិសារអាហារថ្ងៃត្រង់រួមគ្នា** | |
| ១:៣០-២:១០ | ❖ **<u>ការពិភាក្សាក្រុម៖</u>**<br>****<u>ការបែងចែកក្រុមពិភាក្សា</u>** | **លោកបណ្ឌិត**<br>**ប៉ែន សារភាព**<br>ប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការNRDO និងជាសមាជិកក្រុមការងារផ្នែក |

| | | |
|---|---|---|
| | | ធនធានមនុស្សនៃអង្គការគ.ស.ក |
| ២:១០-៣:១៥ | ❖ **<u>ការចែករំលែកអំពីការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក</u>**<br>- **ការកំណត់គោលដៅ**<br>- **ការពិនិត្យលើការងារសាកល្បង**<br>- **ការពិនិត្យលើការងារពាក់កណ្តាលឆ្នាំ** | **លោកបណ្ឌិត ប៉ែន សារភាព** |
| ៣:១៥-៣:៣០ | ❖ សម្រាក**អាហារសម្រន់** | |
| ៣:៣០-៤:៣០ | ❖ **<u>បន្តការចែករំលែកអំពីការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក៖</u>**<br>- ការវាយតម្លៃសមិទ្ធផលការងារប្រចាំឆ្នាំ<br>- សូចនាករសំខាន់ៗសម្រាប់វាយតម្លៃសមិទ្ធផលការងារ<br>- ការវាយតម្លៃបុគ្គលិក និងការផ្តល់មតិកែលម្អ<br>- ជំហានបន្ទាប់<br>▪ **ការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំ**<br>▪ **ការអភិវឌ្ឍន៍សមត្ថភាព**<br>▪ **ផែនការកែលម្អប្រសិទ្ធភាពការងាររបស់បុគ្គលិក**<br>▪ **ផ្សេងៗ**<br>****ការធ្វើការវាយតម្លៃវគ្គ** | **លោកបណ្ឌិត ប៉ែន សារភាព** |
| ៤:៣០-៥:០០ | ***(សំណួរនិងចម្លើយ)*** | |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គ.ស.ក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែរបៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។ អង្គការ គ.ស.ក នឹងយករូបថតនៃវេទិការៀនសូត្រនេះសម្រាប់ការប្រើប្រាស់ផ្លូវការផ្សេងៗ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់* *raingsey.roeung@ccc-cambodia.org*